Vol 5, No 2, July - December 2020, pp: 17 - 26
License: CC BY 4.0

**Faculty Publications**
ISSN: 3008-1017
Title DOI: https://doi.org/10.62458/021024

# Constitution: A Glance at Fundamental Concepts

**Virak Prum***

**ABSTRACT**

This article presents fundamental concepts related to the constitution, beginning with the assertion that the highest law of the land functions as the juridical statute of the state. While the second aspect concerns with various types of constitutions and how customs may aid in interpreting the constitution, the most critical concept is about the need to ensure the constitutionality of laws. It concludes with remarks on why a constitution is needed in the first place.

## ១. ទម្រង់គតិយុត្តរបស់រដ្ឋ និងសញ្ញាណផ្សេងៗនៃរដ្ឋធម្មនុញ្ញ [2]

រដ្ឋត្រូវបានឱ្យនិយមន័យថាជាស្ថាប័ន ឬ ជានីតិបុគ្គលដែលមានអំណាចនយោបាយ។ ក៏ប៉ុន្តែរាល់នីតិបុគ្គលទាំងអស់ត្រូវមានមូលដ្ឋានលើលក្ខន្តិកៈច្បាស់លាស់ ដើម្បីអនុញ្ញាតឱ្យនីតិបុគ្គលនោះអាចដំណើរការបានដូចរូបវន្តបុគ្គល បើគ្មានលក្ខន្តិកៈទេ ក៏គ្មាននីតិបុគ្គលដែរ។

### *រដ្ឋធម្មនុញ្ញជាលក្ខន្តិកៈរបស់រដ្ឋ*

កាលពីសម័យមុន នៅបច្ចឹមប្រទេសទោះក្នុងរបបរាជាធិបតេយ្យក៏ដោយ ក៏ព្រះមហាក្សត្រតោងត្រូវគោរពតាមបទប្បញ្ញត្តិមួយចំនួនដែលព្រះអង្គផ្ទាល់ពុំមានសិទ្ធិកែប្រែឡើយ ឧទាហរណ៍ ដូចជាបែបបទជ្រើសរើសក្សត្រថ្មីដើម្បីបន្តរាជបល្លង្គជាដើម បានសេចក្ដីថា មានបទប្បញ្ញត្តិមួយចំនួនដែលនៅខ្ពស់ជាងឆន្ទៈរបស់ព្រះមហាក្សត្រ។ ក្នុងករណីដែលគ្មានបញ្ញត្តិណាមួយខ្ពស់ជាងឆន្ទៈព្រះមហាក្សត្រទេនោះ អំណាចទាំងអស់មុខតែស្ថិតក្នុងកណ្ដាប់ដៃរបស់មនុស្សតែម្នាក់ ជាជាងរបស់ស្ថាប័ន។ ក្នុងន័យនេះ ប្រទេសនោះគ្មាន "ស្ថាប័ន" ទេ ពោលគឺគ្មាន "រដ្ឋ" ក្នុងអត្ថន័យគតិយុត្តឡើយ។

### *រដ្ឋធម្មនុញ្ញជាឧបករណ៍ដើម្បីកំណត់ព្រំដែនអំណាច*

តាមទ្រឹស្ដី អំណាចក្នុងន័យស្ថាប័ន គឺជាការផ្ទេរអំណាចពីបុគ្គលដែលអ្នកដឹកនាំ ទៅអោយអង្គភាព (រដ្ឋ) ដែលតាមរយៈការប្រគល់នេះ អ្នកដឹកនាំត្រូវប្រែក្លាយមកជាអ្នកបម្រើរដ្ឋទៅវិញ ព្រោះថាលក្ខន្តិកៈរបស់រដ្ឋ ឬ រដ្ឋធម្មនុញ្ញនេះ តែងតែមានដាក់លក្ខខណ្ឌផ្សេងៗលើអ្នកដឹកនាំមុនពេលចេញច្បាប់

* Virak Prum, PhD
CamEd Business School
Email: pvirak@cam-ed.com

និងបទបញ្ជា ដែលមានអានុភាពអនុវត្តលើអ្នកដឹកនាំនោះដែរ។ ក្រោយពេលចេញច្បាប់ ឬ បទបញ្ជានានា អ្នកដឹកនាំពុំអាចកែប្រែអត្ថបទគតិយុត្តទាំងនោះតាមចិត្តចង់ឡើយ តែត្រូវអនុវត្តតាមលក្ខខណ្ឌដែលបានចែងទុកជាមុន។ ដូចនេះ អំណាចដែលត្រូវបានប្រគល់ឱ្យស្ថាប័ន ជាលក្ខខណ្ឌចាំបាច់មួយនៃអ្វីដែលគេហៅថា "នីតិរដ្ឋ" (État de droit) ដែលផ្ទុយពីរដ្ឋប៉ូលីស (État de police) ដែលអ្នកដឹកនាំអាចធ្វើអ្វីៗបានតាមចិត្ត។ គឺក្នុងន័យនេះហើយដែលគេអាចនិយាយបានថា រដ្ឋធម្មនុញ្ញពុំមែនត្រឹមតែជាឧបករណ៍ដើម្បីប្រែក្លាយអំណាចផ្ទាល់ខ្លួនមកជាអំណាចស្ថាប័នប៉ុណ្ណោះទេ តួនាទីមួយទៀតរបស់រដ្ឋធម្មនុញ្ញគឺដើម្បីដាក់កម្រិតព្រំដែនលើការប្រើអំណាចនេះតែម្តង ដើម្បីការពារសិទ្ធិសេរីភាពបុគ្គល។ ហេតុដូច្នេះហើយទើបមាត្រា១៦ នៃសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋឆ្នាំ១៧៨៩ (Déclaration des Droits de l'Homme et du Citoyen) ចែងថា "*សង្គមណាដែលពុំមានការធានាការគោរពសិទ្ធិមនុស្ស និងការបែងចែកអំណាចទេ សង្គមនោះគ្មានរដ្ឋធម្មនុញ្ញឡើយ។*" ក្នុងន័យនេះហើយដែល "របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ" ត្រូវមានការកំណត់លក្ខខណ្ឌជាច្រើនអំពីការប្រើអំណាច។

### *រដ្ឋធម្មនុញ្ញនយោបាយ និង រដ្ឋធម្មនុញ្ញសង្គម*

រដ្ឋធម្មនុញ្ញដែលកើតចេញពីស្ថាប័នភាវូនីយកម្មអំណាច (institutionalisation de pouvoir) គឺរដ្ឋធម្មនុញ្ញក្នុងន័យនយោបាយ (constitution politique)។ អតីតព្រឹទ្ធបុរសលោក Maurice Hauriou បានលើកឡើងថា នៅពីក្រោយរដ្ឋធម្មនុញ្ញតាមន័យនយោបាយ នៅមានរដ្ឋធម្មនុញ្ញតាមន័យសង្គមមួយទៀត (constitution sociale) ដែលបង្ហាញ និងពន្យល់ពីមនោសញ្ចេតនារបស់ប្រជាជាតិ ហើយដែលគេតែងប្រទះឃើញក្នុងអារម្ភកថារដ្ឋធម្មនុញ្ញ ដែលចែងអំពីគោលបំណងក្នុងការបង្កើតរដ្ឋ ក៏ដូចជាផែនការអភិវឌ្ឍន៍របស់សង្គមនោះ ពោលគឺរដ្ឋធម្មនុញ្ញក្នុងន័យសង្គមជាអ្នកចង្អុលបង្ហាញទិសដៅនិងត្រួសត្រាយផ្លូវឱ្យសង្គមនោះដើរតាម។

## ២. ប្រភេទនៃរដ្ឋធម្មនុញ្ញ

យើងតែងបែងចែកជាពីរប្រភេទ រដ្ឋធម្មនុញ្ញតាមទំនៀមទម្លាប់ និងរដ្ឋធម្មនុញ្ញសរសេរ។ ប៉ុន្តែគេត្រូវកត់សម្គាល់ថា ការបែងចែកនេះពុំមានលក្ខណៈដាច់ខាតទេ ព្រោះថារដ្ឋធម្មនុញ្ញតាមទំនៀមទម្លាប់ ក៏មានបទប្បញ្ញត្តិសរសេរមួយចំនួន រីឯរដ្ឋធម្មនុញ្ញសរសេរ ពេលខ្លះក៏ត្រូវបានបកស្រាយតាមទំនៀមទម្លាប់ដែរ។

### *រដ្ឋធម្មនុញ្ញទំនៀមទម្លាប់ (រដ្ឋធម្មនុញ្ញឥតសរសេរ)*

សព្វថ្ងៃនេះ រដ្ឋធម្មនុញ្ញបែបនេះមានចំនួនតិចណាស់។ ក្នុងចំណោមរដ្ឋធំៗ មានតែចក្រភពអង់គ្លេសតែប៉ុណ្ណោះដែលនៅប្រើរដ្ឋធម្មនុញ្ញទំនៀមទម្លាប់នេះ ក៏ប៉ុន្តែ រដ្ឋធម្មនុញ្ញទំនៀមទម្លាប់របស់អង់គ្លេសមានរាប់បញ្ចូលនូវបទប្បញ្ញត្តិសរសេរជាច្រើនៈ អត្ថបទ Magna Carta ១២១៥, The Petition of Rights ១៦២៨, Habeas Corpus ១៦៧៩, Bill of Rights ១៦៨៩, ច្បាប់បង្កើតប្រទេស ១៧០១ និងច្បាប់ដទៃទៀត រួមមានច្បាប់បង្កើតសហគមន៍អឺរ៉ុប ១៩៧២, និងច្បាប់សិទ្ធិមនុស្ស ១៩៩៨ ជាដើម។ល។ នៅអង់គ្លេស អត្ថបទគតិយុត្តទាំងអស់នេះសុទ្ធតែមានតម្លៃជារដ្ឋធម្មនុញ្ញ។ ឧទាហរណ៍ជាក់ស្តែងដែលបញ្ជាក់ពីតម្លៃនៃទំនៀមទម្លាប់ (មិនសរសេរ) នៅអង់គ្លេសរួមមាន ការរំលាយសភាជាន់ទាប កាតព្វកិច្ចរបស់ព្រះមហាក្សត្រត្រូវជ្រើសតាំងនាយករដ្ឋមន្ត្រីពីប្រធានបក្សឈ្នះឆ្នោតច្រើនជាងគេ បំរាមមិនឱ្យព្រះមហាក្សត្រធ្វើជាអធិបតីគណរដ្ឋមន្ត្រី...ជាដើម សុទ្ធសឹងជាវិធានទំនៀមទម្លាប់ឥតសរសេរទាំងអស់ដែលត្រូវបានគេទទួលស្គាល់តៗគ្នាថាមានតម្លៃ គតិយុត្តស្មើរដ្ឋធម្មនុញ្ញនៅអង់គ្លេស។[3]

### *រដ្ឋធម្មនុញ្ញសរសេរ*

រដ្ឋធម្មនុញ្ញសរសេរដែលមានវ័យចំណាស់ជាងគេ មានដើមកំណើតនៅរដ្ឋ Virginia ខែមិថុនា ឆ្នាំ ១៧៧៦[4] មានរដ្ឋធម្មនុញ្ញបារាំងឆ្នាំ១៧៩១ ដែលមានបញ្ចូលសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ។ រដ្ឋធម្មនុញ្ញសរសេរចាប់ផ្តើមមានឥទ្ធិពលតាំងពីពេលនោះមក លាតសន្ធឹងលើទឹកដីផ្សេងទៀតលើពិភពលោកទាំងមូល។

រដ្ឋធម្មនុញ្ញសរសេរមានអត្ថប្រយោជន៍ខ្ពស់ត្រង់ថា ប្រជាពលរដ្ឋងាយយល់ដឹងពីខ្លឹមសារទាំងមូលរបស់រដ្ឋធម្មនុញ្ញ ដោយសារតែខ្លឹមសារទាំងនោះត្រូវបានចារឹកទុកនៅក្នុងអត្ថបទតែមួយ។ អត្ថប្រយោជន៍មួយទៀតនៅត្រង់ថា រដ្ឋធម្មនុញ្ញសរសេរមានលក្ខណៈប្រជាធិបតេយ្យជាង ព្រោះ (នៅប្រទេសមួយចំនួន) ប្រជាពលរដ្ឋអាចត្រូវបានគេសួរយោបល់នៅពេលចង់ធ្វើវិសោធនកម្ម តាមរយៈការធ្វើប្រជាមតិ (referendum) ជាដើម។

### *សារៈសំខាន់របស់ទំនៀមទម្លាប់ក្នុងការបកស្រាយរដ្ឋធម្មនុញ្ញសរសេរ*

ដើម្បីឱ្យទំនៀមទម្លាប់មួយអាចទទួលបាននូវតម្លៃជារដ្ឋធម្មនុញ្ញ ទំនៀមទម្លាប់នោះត្រូវបំពេញលក្ខខណ្ឌបួនះ១. ទំនៀមទម្លាប់នោះត្រូវបានគេប្រើជាច្រើនលើកច្រើនសារក្នុងរយៈពេលយូរអង្វែងពោលគឺពុំមែនជាការអនុវត្តតែម្តងម្កាលនោះទេ។ ២. ការបកស្រាយដដែលៗនោះមានខ្លឹមសារដូចគ្នា។

៣. ការបកស្រាយនោះមានមូលហេតុ អំណះអំណាងច្បាស់លាស់។ ៤. ការបកស្រាយនោះត្រូវបាន ស្ថាប័នធម្មនុញ្ញទទួលស្គាល់ជាកុងសង់ស៊ុស។

និយាយឱ្យចំ គឺទំនៀមទម្លាប់នោះត្រូវបានគេទទួលស្គាល់ថា មានចារឹកលក្ខណៈចាប់បង្ខំអាចអនុវត្តបាន (opinio juris)។

ក្នុងទិដ្ឋភាពជាក់ស្តែង ឋានៈរបស់ទំនៀមទម្លាប់ក្នុងនីតិឋានានុក្រមពុំមានលក្ខណៈជាក់លាក់ទេ ព្រោះថា តាមទ្រឹស្តី ដើម្បីឱ្យព្រឹត្តហេតុ (ទំនៀមទម្លាប់) មួយអាចយកជាការបាន លុះត្រាតែមានបញ្ញត្តិគតិយុត្តចែងទុកជាមុន ដែលបើកលទ្ធភាពឱ្យទទួលស្គាល់ទំនៀមទម្លាប់នោះ។ គេតែងសង្កេតឃើញក្នុងក្រមរដ្ឋប្បវេណី ក៏ដូចជាក្រមពាណិជ្ជកម្ម នូវបញ្ញត្តិមួយដែលចែងថា "ក្នុងករណីដែលច្បាប់ចែងពុំច្បាស់ ឬ ពុំមានចែង ចៅក្រមត្រូវដោះស្រាយវិវាទដោយប្រើវិធានទំនៀមទម្លាប់។" ក្នុងករណីនេះ ទំនៀមទម្លាប់ត្រូវបានចាត់ទុកដូចជាប្រភពមួយនៃច្បាប់។ ចុះក្នុងរដ្ឋធម្មនុញ្ញ តើអាចមានទំនៀមទម្លាប់ដែលមានតំលៃជារដ្ឋធម្មនុញ្ញដែរ ឬ ទេ? មិនអាចទេ ព្រោះថាលក្ខខណ្ឌដែលតម្រូវឱ្យមានបញ្ញត្តិខ្ពស់ជាងទុកជាមុន ពុំអាចសម្រេចបានឡើយ ដោយសារគ្មានអ្វីខ្ពស់ជាងរដ្ឋធម្មនុញ្ញទេ។

ម៉្យាងវិញទៀត ក្នុងករណីដែលទំនៀមទម្លាប់មានលក្ខណៈផ្ទុយពីច្បាប់ជាធរមាន ទំនៀមទម្លាប់នោះពុំអាចយកមកអនុវត្តបាននោះទេ។ ដូច្នេះក្នុងការអនុវត្ត មានតែករណី *praeter legem* តែមិនអាចមាន *contra legem* ទេ។

### *តួនាទីរបស់ទំនៀមទម្លាប់ដែលមានតម្លៃជារដ្ឋធម្មនុញ្ញ*

ក្នុងទ្រឹស្តីច្បាប់មានទំនៀមទម្លាប់ពីរប្រភេទ៖ ទំនៀមទម្លាប់ដែលគេយកមកប្រើដើម្បីបំពេញភាពខ្វះចន្លោះ ឬ ស្រពេចស្រពិលរបស់ច្បាប់ (*praeter legem*) និងទំនៀមទម្លាប់ផ្ទុយច្បាប់ (*contra legem*)។ គេគួរកត់សម្គាល់ថា បាតុភូតដែលញាំងឱ្យច្បាប់សរសេរមានតម្លៃខ្ពស់ជាងទំនៀមទម្លាប់ ជាបាតុភូតថ្មី ព្រោះមុនសតវត្សទី១៦ ច្បាប់ភាគច្រើនស្ថិតក្នុងទម្រង់ជាទំនៀមទម្លាប់នៅឡើយ។ ម៉្យាងវិញទៀត ទំនៀមទម្លាប់ដែលមានតម្លៃជារដ្ឋធម្មនុញ្ញដើរតួនាទីយ៉ាងសំខាន់ក្នុងការបកស្រាយបញ្ញត្តិដែលមានលក្ខណៈស្រពេចស្រពិល ក៏ដូចជាដើម្បីថ្លឹងថ្លែងរកឱ្យមានសមតុលនៃអំណាច។

## ៣. ឧត្តមានុភាពនៃរដ្ឋធម្មនុញ្ញ (ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់) [5]

រដ្ឋធម្មនុញ្ញនឹងគ្មានឧត្តមានុភាពទេ បើសិនជាស្ថាប័នរដ្ឋអាចចេញបញ្ញត្តិរំលោភលើរដ្ឋធម្មនុញ្ញបាន។ ដោយសាររដ្ឋធម្មនុញ្ញមានឧត្តមានុភាពនេះហើយ ទើបគេអាចរំលាយច្បាប់ និងបញ្ញត្តិឯទៀតដែលគេយល់ឃើញថាមានចរឹកផ្ទុយនឹងរដ្ឋធម្មនុញ្ញ។ ក្នុងករណីជាក់ស្តែង រដ្ឋធម្មនុញ្ញអាចត្រូវបានរំលោភបំពាន ដោយសេចក្តីសម្រេចរបស់អំណាចនីតិប្រតិបត្តិ ដោយតុលាការ និងដោយបុគ្គលឯកជនផងដែរ។ ប៉ុន្តែនៅទីនេះ នីតិរដ្ឋធម្មនុញ្ញផ្តោតសំខាន់តែទៅលើការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់។

### *មូលដ្ឋានគ្រឹះនៃការត្រួតពិនិត្យធម្មនុញ្ញភាព*

មូលដ្ឋានគ្រឹះដែលបង្កើតឱ្យមានលទ្ធភាពត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ គឺនៅត្រង់ថា បើសិនជាគ្មានការត្រួតពិនិត្យណាមួយទេ អំណាចនីតិបញ្ញត្តិអាចរំលោភរដ្ឋធម្មនុញ្ញតាមចិត្ត ដែលនាំឱ្យគេគិតថា រដ្ឋធម្មនុញ្ញគ្មានតម្លៃលើច្បាប់ ឬ គ្មានកាតព្វកិច្ចចាប់បង្ខំឱ្យគេអនុវត្ត។ ម៉្យាងវិញទៀត នៅក្នុងប្រព័ន្ធនយោបាយបែបប្រជាធិបតេយ្យ ច្បាប់ត្រូវបានធ្វើឡើងដោយប្រជាជន ដូចនេះ ការបង្កើតឱ្យមានស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ដែលមិនមែនជាប្រជាជនផ្ទាល់ គឺជារឿងល្អ ព្រោះថាស្ថាប័ននេះមានអំណាចត្រួតពិនិត្យឆន្ទៈរបស់ប្រជាជនបាន។ ក្នុងន័យនេះ អ្នកខ្លះយល់ថាប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពបែបនេះ ពុំមានលក្ខណៈប្រជាធិបតេយ្យទេ។ សភាធម្មនុញ្ញនីមួយៗ ត្រូវជ្រើសរើសរវាងឧត្តមានុភាពនៃរដ្ឋធម្មនុញ្ញ និង ឧត្តមានុភាពនៃប្រជាធិបតេយ្យ។ តើធ្វើយ៉ាងណាដើម្បីពន្យល់ថាអត្ថិភាពនៃស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពពុំមានលក្ខណៈផ្ទុយនឹងប្រជាធិបតេយ្យនោះ?

### *ការពារការត្រួតពិនិត្យធម្មនុញ្ញភាពក្នុងរបបប្រជាធិបតេយ្យ*

ប្រមូលផ្តុំនូវគំនិតពីរ:

ទី១. ប្រជាធិបតេយ្យពុំមែនបានន័យថា ត្រូវផ្តល់អំណាចឱ្យទៅតែមតិភាគច្រើននៅក្នុងសភានោះទេ។ គេអាចពន្យល់ប្រជាធិបតេយ្យតាមន័យចង្អៀត ឬ តាមន័យទូលាយ។ ក្នុងន័យចង្អៀត ប្រជាធិបតេយ្យគឺជាអំណាចរបស់ប្រជាជនផ្ទាល់ បានន័យថា ប្រជាធិបតេយ្យមានតែក្នុងរូបភាពប្រជាធិបតេយ្យដោយផ្ទាល់ (démocratie directe) តែប៉ុណ្ណោះ ដែលក្នុងសម័យកាលបច្ចុប្បន្ននេះ គេពុំឃើញមានអនុវត្តបានឡើយ។ យ៉ាងណាក៏គេតែងសង្កេតឃើញប្រជាជនត្រូវជ្រើសរើសអ្នកដឹកនាំ ពោលគឺពុំអាចដឹកនាំដោយផ្ទាល់ខ្លួននោះទេ ដូច្នេះការត្រួតពិនិត្យធម្មនុញ្ញភាពរបស់ច្បាប់/ឆន្ទៈរបស់ថ្នាក់ដឹកនាំ ពុំមែនជាការត្រួតពិនិត្យឆន្ទៈរបស់ប្រជាជនឡើយ បានន័យថាគេអាចធ្វើការត្រួតពិនិត្យធម្មនុញ្ញភាពបាន។

ក្នុងន័យទូលាយ ប្រជាធិបតេយ្យដោយតំណាង (démocratie représentative) ក៏ត្រូវបានគេទទួលស្គាល់ថាជាទម្រង់មួយនៃលទ្ធិប្រជាធិបតេយ្យដែរ ប៉ុន្តែប្រជាធិបតេយ្យនេះ ពុំសំដៅតែទៅលើមតិភាគច្រើនឡើយ ព្រោះត្រូវទទួលស្គាល់ និងការពារផលប្រយោជន៍របស់មតិភាគតិចដែរ។ ដូចនេះ ការត្រួតពិនិត្យធម្មនុញ្ញភាពអាចជាឧបករណ៍មួយដើម្បីការពារផលប្រយោជន៍មតិភាគតិច។

ទី២. ទាក់ទងការត្រួតពិនិត្យធម្មនុញ្ញភាពនេះ គេត្រូវកត់សម្គាល់ថា ពុំមែនច្បាប់ទាំងអស់សុទ្ធតែសំដែងនូវឆន្ទៈរបស់ប្រជាជន ឬ ឆន្ទៈទូទៅឡើយ ព្រោះថារដ្ឋធម្មនុញ្ញតែងចែងពីលក្ខខណ្ឌនានាសម្រាប់ឱ្យអ្នកធ្វើច្បាប់ (សភា) ត្រូវគោរពតាម។ ពេលដែលសភាបានគោរពតាមលក្ខខណ្ឌទាំងនោះ សភានោះបានសម្តែងនូវឆន្ទៈទូទៅ។ តែផ្ទុយទៅវិញ បើសភាពុំបានគោរពតាមលក្ខខណ្ឌដែលរដ្ឋធម្មនុញ្ញបានចែងទេនោះ ច្បាប់ដែលត្រូវបានអនុម័តឡើងពុំសម្តែងឆន្ទៈទូទៅឡើយ។ ក្នុងន័យនេះ ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ដែលពុំបានគោរពតាមលក្ខខណ្ឌទាំងនោះ ពុំផ្ទុយនឹងឆន្ទៈទូទៅទេ ពោលគឺពុំផ្ទុយនឹងប្រជាធិបតេយ្យឡើយ។

ក្នុងន័យប្រជាធិបតេយ្យខាងលើនេះ ក្នុងករណីដែលស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពចេញសេចក្តីសម្រេចដែលពុំមានលក្ខណៈត្រឹមត្រូវ តើគេអាចការពារលទ្ធិប្រជាធិបតេយ្យតាមវិធីណា? វិធីសាស្ត្រតែមួយគត់ គឺតាមរយៈការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ព្រោះថារដ្ឋធម្មនុញ្ញកើតចេញពីសភាធម្មនុញ្ញដែលជាអ្នកតំណាងឱ្យឆន្ទៈប្រជាពលរដ្ឋ។ បញ្ញត្តិរដ្ឋធម្មនុញ្ញថ្មីមានអានុភាពលើសេចក្តីសម្រេចមុនៗរបស់ស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាព។ ដោយសារថា វិសោធនកម្មរដ្ឋធម្មនុញ្ញធ្វើឡើងដោយសភាដែលជាអ្នកតំណាងប្រជាពលរដ្ឋ វិសោធនកម្មគឺជាការសម្តែងឆន្ទៈថ្មីដែលជាឆន្ទៈកំពូល (ច្បាប់កំពូល) របស់ប្រជាពលរដ្ឋ។ តាមរយៈនេះ បានន័យថា គឺប្រជាពលរដ្ឋដែលជាម្ចាស់អំណាចនេះហើយដែលជាអ្នកមានសិទ្ធិកែប្រែសេចក្តីសម្រេចរបស់ស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាព។

### *ទ្រឹស្តីបកស្រាយរដ្ឋធម្មនុញ្ញតាមបែបពិតនិយម*

ពួកពិតនិយមជឿថា ដើម្បីបង្ហាញឱ្យឃើញនូវការរំលោភរដ្ឋធម្មនុញ្ញណាមួយ គេត្រូវតួសបញ្ជាក់ឱ្យច្បាស់ជាបឋមនូវអត្ថន័យជាក់លាក់របស់បញ្ញត្តិធម្មនុញ្ញណាមួយនោះ។ ប៉ុន្តែ ជារឿយៗបញ្ញត្តិរដ្ឋធម្មនុញ្ញតែងមានន័យទូលាយ និងស្រពេចស្រពិលដែលទាមទារឱ្យមានការបកស្រាយតាមបែបគតិយុត្តទើបបាន។ ប៉ុន្តែ ជាអកុសល អត្ថន័យគតិយុត្តជាក់លាក់ ពេលខ្លះពុំមានចែងច្បាស់ក្នុងរដ្ឋធម្មនុញ្ញទេ ដូចនេះ ការបកស្រាយនូវអត្ថន័យពាក្យពេចន៍ណាមួយក្នុងរដ្ឋធម្មនុញ្ញ ត្រូវធ្វើតាមរយៈការចេញសេចក្តីសម្រេចជាក់លាក់ ជាជាងការសង្កេតធម្មតា។ ហេតុដូច្នេះហើយ ទើបគេអាចនិយាយបាន

ថា នៅពេលច្បាប់មួយត្រូវបានបកស្រាយ អ្នកដែលធ្វើច្បាប់ពិតប្រាកដ ពុំមែនអ្នកអនុម័តច្បាប់នោះទេ តែអ្នកបកស្រាយនេះតែម្តង ព្រោះអ្នកបកស្រាយនេះចេញជាសេចក្តីសម្រេចដែលយកទៅអនុវត្ត។ ក្នុងវិស័យរដ្ឋធម្មនុញ្ញ ក៏យ៉ាងដូច្នេះដែរ។ ក្នុងទ្រឹស្តីពិតនិយមនេះ ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ គឺអាស្រ័យទៅលើឆន្ទៈរបស់អ្នកត្រួតពិនិត្យ ពុំមែនអាស្រ័យលើឆន្ទៈរបស់ប្រជាពលរដ្ឋទេ ពោលគឺពុំមានលក្ខណៈប្រជាធិបតេយ្យឡើយ។ ពួកនេះត្រូវបានគេឱ្យឈ្មោះថា "ការគ្រប់គ្រង ឬ រដ្ឋាភិបាលរបស់ចៅក្រម" (ឧទាហរណ៍ៈ តួនាទីរបស់តុលាការ ពិសេសរបស់តុលាការកំពូលនៅសហរដ្ឋអាមេរិក)។

### *ទ្រឹស្តីបកស្រាយរដ្ឋធម្មនុញ្ញសម័យទំនើប*

អ្នកទ្រឹស្តីសម័យទំនើប ព្យាយាមពន្យល់ពីភាពចាំបាច់ក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ដោយចៀសវាងអំណះអំណាងក្នុងន័យនយោបាយ ពួកគេពន្យល់ថា ការបកស្រាយរដ្ឋធម្មនុញ្ញជារឿងចាំបាច់ ប៉ុន្តែ ការបកស្រាយពុំអាស្រ័យតែទៅលើឆន្ទៈរបស់ចៅក្រមឡើយ។ សម្រាប់អ្នកខ្លះ ការបកស្រាយរបស់ចៅក្រម ត្រូវពឹងផ្អែកលើអំណះអំណាងច្បាស់លាស់ ទៅលើអត្ថន័យរបស់ពាក្យពេចន៍ ជាជាងការខំដាក់កម្រិតលើអំណាចនយោបាយរបស់អ្នកធ្វើច្បាប់ (សភា)។ អ្នកទ្រឹស្តីខ្លះទៀតយល់ថា តួនាទីរបស់ចៅក្រមផ្លាស់ប្តូរទៅតាមស្ថានភាព បានន័យថា ចៅក្រមអាចប្រកាសមោឃភាពនៃច្បាប់ណាមួយដោយសារអធម្មនុញ្ញភាពបាន ប៉ុន្តែសភាដែលចង់រក្សាបញ្ញត្តិនោះ (ជំហរនយោបាយនោះ) អាចបញ្ចូលបញ្ញត្តិនោះក្នុងរដ្ឋធម្មនុញ្ញនាពេលក្រោយបាន។

### *ប្រភេទនៃការត្រួតពិនិត្យធម្មនុញ្ញភាព*

ការត្រួតពិនិត្យធម្មនុញ្ញភាពអាចប្រព្រឹត្តទៅបានក្រោមរូបភាពពីរយ៉ាង គឺការត្រួតពិនិត្យធម្មនុញ្ញភាពមុនពេលប្រកាសឱ្យប្រើច្បាប់ (a priori) និងការត្រួតពិនិត្យធម្មនុញ្ញភាពក្រោយពេលប្រកាសឱ្យច្បាប់ ចូលជាធរមាន (a posteriori)។ ការត្រួតពិនិត្យធម្មនុញ្ញភាព a priori មានអត្ថប្រយោជន៍ត្រង់ថា វាធានាឱ្យមាននូវសុវត្ថិភាពគតិយុត្ត ព្រោះលទ្ធភាពនៃការកកើតវិវាទត្រូវបានគេបញ្ចៀសជាមុនរួចជាស្រេច មុនច្បាប់ចូលជាធរមាន។ ក៏ប៉ុន្តែ ការត្រួតពិនិត្យ a priori ក៏មានផលវិបាកពីរយ៉ាងដែរ ទីមួយ ជាផលវិបាកនយោបាយ ព្រោះស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពត្រូវផ្តល់យោបល់ដែលមានសារៈសំខាន់លើបញ្ហានយោបាយដែលកំពុងតែក្តៅគគុក ដែលមតិភាគច្រើននៅក្នុងសភាទើបបានអនុម័ត។ ទីពីរ គឺត្រង់ថាស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពត្រូវបង្ខំចិត្តធ្វើការវិនិច្ឆ័យទៅលើគុណភាពរបស់ច្បាប់មួយ ក្នុងខណៈដែលច្បាប់នោះពុំទាន់ត្រូវបានអនុវត្តនៅឡើយ។ ផ្ទុយទៅវិញ ទោះបីជាការត្រួតពិនិត្យ a posteriori

អាចបញ្ចៀសនូវផលវិបាកទាំងពីរខាងលើបានក៏ដោយ ក៏វានៅមានផលវិបាកមួយខ្លួនឯងដែរ ត្រង់ថា ច្បាប់មិនល្អ (ច្បាប់អធម្មនុញ្ញ) ត្រូវបានគេអនុវត្តរហូតដល់មានគេប្ដឹង។

ក្នុងប្រព័ន្ធច្បាប់ពិភពលោកសព្វថ្ងៃនេះ គេបែងចែករវាងការត្រួតពិនិត្យតាមបែបអរូបិយ (in abstracto) ពោលគឺមុនច្បាប់ចូលជាធរមាន ហៅម៉្យាងទៀតថា controle par voie d'action (នេះជាប្រព័ន្ធដែលអនុវត្តនៅសាធារណៈរដ្ឋបារាំងសព្វថ្ងៃ) និងការត្រួតពិនិត្យតាមរយៈរឿងក្ដី ដែលត្រូវអនុវត្តតាមយុត្តាធិការពិសេសណាមួយ នេះជាករណីនៅសហរដ្ឋអាមេរិក នៅអ៊ីតាលី នៅអាឡឺម៉ង់ ជាដើម ដែលគេហៅថា controle par voie d'exception ដែលកើតឡើងតែក្រោយពេលច្បាប់ណាមួយចូលជាធរមាន (ឧទាហរណ៍ ពេលភាគីក្នុងរឿងក្ដីណាមួយលើកពីអធម្មនុញ្ញនៃច្បាប់ណាមួយនៅចំពោះមុខតុលាការ)។

## ៤. សន្និដ្ឋាន

ហេតុអ្វីបានជាចាំបាច់ត្រូវមានរដ្ឋធម្មនុញ្ញ? [6] មូលហេតុទីមួយគឺនៅត្រង់ថា គេពិបាកធ្វើការកែប្រែរដ្ឋធម្មនុញ្ញណាស់។[7] នៅកម្ពុជាបច្ចុប្បន្ន ការកែប្រែបញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញទាមទារមតិគាំទ្រភាគច្រើនពីរ ភាគបី យ៉ាងតិចនៃសមាជិករដ្ឋសភាទាំងមូល។ ការដែលគេធ្វើឲ្យមានការលំបាកក្នុងការកែប្រែនេះគឺដោយសាររដ្ឋធម្មនុញ្ញឱបក្រសោបលើកតម្កើងនូវគុណតម្លៃដ៏មានអត្ថន័យដ៏ជ្រាលជ្រៅបំផុតជាគុណតម្លៃជាមូលដ្ឋានដែលសង្គមបែបសេរីត្រូវការខានមិនបានពីជំនាន់មួយទៅជំនាន់មួយទៀត។ មូលហេតុទីពីរ ស្ថិតនៅត្រង់ថា រាល់បញ្ហាសំខាន់ៗរបស់ជាតិត្រូវបានចារឹកទុកក្នុងអត្ថបទតែមួយខ្លីល្មមងាយអាន។ ទោះជាពេលខ្លះ រដ្ឋធម្មនុញ្ញចែងថា បញ្ហាណាមួយនឹងត្រូវគ្រប់គ្រងដោយច្បាប់ដោយឡែកក្ដី ក៏ប្រជាពលរដ្ឋនៅមានជំនឿថា ច្បាប់នោះ ពុំអាចងាករេចេញពីមាគ៌ាដែលរដ្ឋធម្មនុញ្ញបានត្រួសត្រាយឲ្យឡើយ។

ក្រៅពីដើរតួនាទីជាអ្នកធានាការពារសេរីភាពជាមូលដ្ឋានរបស់ពលរដ្ឋ និងតួនាទីជាអ្នកត្រួសត្រាយចង្អុលផ្លូវឲ្យរដ្ឋដើរតាមនេះ រដ្ឋធម្មនុញ្ញនៅមានចរិតលក្ខណពិសេសម្យ៉ាងទៀតដោយដើរតួជាអ្នកថែរក្សាព្រលឹងជាតិពីជំនាន់មួយទៅជំនាន់មួយ។ តាមរយៈវិធីសាស្ត្រនៃការបកស្រាយ គេដឹងថាអត្ថន័យនៃបញ្ញត្តិរបស់រដ្ឋធម្មនុញ្ញអាចវិវត្តទៅតាមការវិវត្តល្អរបស់សង្គម។

# REFERENCES

[1] Dr. Virak Prum is an Adjunct Professor of Law and teaches courses in *Cambodian Business Law* program at CamEd Business School. Professor Virak holds LLB, LLM (Japan), PhD (Japan). Article submitted in November 2018.

[2] *See* Bernard Chantebout (2008). *Droit Constitutionnel*. Paris: Sirey Université, 25 edition.

[3] *See, e.g.,* A W Bradley, K D Wing & C J S Knight (2015). *Constitutional & Administrative Law*. London: Person.

[4] http://edu.lva.virginia.gov/online_classroom/shaping_the_constitution/doc/va_constitution (accessed in November 2018)

[5] *See* Francis Hamon, Michel Troper, George Burdeau (2001). *Droit Constitutionnel*. Paris: LGDJ. *See* also Francis Hamon and Michel Troper (2017). *Droit Constitutionnel*. Issy-les-Moulineaux: LGDJ, 37 ed.

[6] I initially published a longer answer to this question as an op ed on Phnom Penh Post (Khmer version) on June 08, 2015.

[7] *See* Erwin Chemerinsky (2011). *Constitutional Law: Principles and Policies*. New York: Wolters Kluwer, 4 ed.